**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១២២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ៦ មាត្រា ៧ និងមាត្រា ១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រាមួយ .-**

មាត្រា ៦ មាត្រា ៧ និងមាត្រា ១១ នៃអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ត្រូវបានកែសម្រួល ដូចតទៅ ÷

**មាត្រា ៦ .- ថ្មី**

អភិបាលរាជធានី ខេត្ត ត្រូវផ្ញើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ។

អភិបាលរាជធានី ខេត្តត្រូវជូនដំណឹងជាសាធារណៈអំពីពេលវេលានិងទីកន្លែងនៃកិច្ចប្រជុំផ្សព្វផ្សាយ។ សេចក្តីជូនដំណឹងនេះ ត្រូវបិទឱ្យសាធារណជនដឹង យ៉ាងតិច ៣ (បី) ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយក្នុងកន្លែងដែលងាយឃើញ នៅក្នុងភូមិ ឬនៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព ក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធត្រូវរៀបចំធ្វើនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ។ ក្នុងកិច្ចប្រជុំនោះ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬ តំណាងគណៈកម្មការរដ្ឋបាលត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យ បំភ្លឺពីបញ្ញាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនឹងការវិនិច្ឆ័យដែលបានលើកឡើង។

កិច្ចប្រជុំបន្ថែមសម្រាប់ថ្នាក់ភូមិ នឹងត្រូវបានរៀបចំប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋានចាត់ទុកថាជាការចាំបាច់។

**មាត្រា ៧ .- ថ្មី**

មន្ត្រីកំណត់ព្រំដីត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យឱ្យបានមុន ៣ (បី) ថ្ងៃ យ៉ាងតិច។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួនតាមរបៀប ដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង។

បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដីត្រូវគោរពគោលការណ៍ ដូចខាងក្រោម ÷

ក- បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំមានវត្តមាន ហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង។

ខ- បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច (ក) នៃមាត្រានេះ មិនអាចធ្វើទៅបានឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូប ជាលាយល័ក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ ទាក់ទងនឹងព្រំដី។

គ- ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់នឹងដីសាធារណៈឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដីត្រូវកំណត់ដោយអនុលោមតាមចំណុច(ក)ឬ(ខ)នៃកថាខណ្ឌ ទី ២ មាត្រា ៧ ថ្មីនៃអនុក្រឹត្យនេះ។

ឃ- វិវាទទាំងអស់អំពីព្រំប្រទល់ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសម្រុះសម្រួល និងដោះស្រាយវិវាទក្រោមមាត្រា ១២ នៃអនុក្រឹត្យនេះ។

**មាត្រា ១១ .- ថ្មី**

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមាន ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដីត្រូវមានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៅកន្លែងដែលងាយមើលឃើញសម្រាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ។

អាជ្ញាធររាជធានី ខេត្ត ត្រូវផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យ តាមសំណើរបស់គណៈកម្មការរដ្ឋបាល។

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ អាចកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់ នៃជនណាមួយ។ ការកែតម្រូវផ្សេងៗ ក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធ ដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ។

**មាត្រាពីរ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមឡាយហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ